**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

# សមិទ្ធផលឆ្នាំសិក្សា ២០១៥-២០១៦

## គោលនយោបាយក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

១- ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

២- ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

## ១- សមិទ្ធផលតាមអនុវិស័យ

### ១.១ អនុវិស័យ ការអប់រំកុមារតូច

សាលាមត្តេយ្យសិក្សាទូទាំងប្រទេសសរុប ៧ ២៤១ សាលា/កន្លែង៖ រដ្ឋ ៤ ០១៤ ឯកជន ៣៩៣ និងសហគមន៍ ២ ៨៣៤។ កុមារអាយុពី ០ ទៅ ៥ឆ្នាំ ទទួលសេវាអប់រំសរុប ៤២៦ ០២៥ នាក់ ស្រី ៥០,២៩ ភាគរយ។ កុមារអាយុ ៥ឆ្នាំ ទទួលបានសេវាអប់រំ ៦៦,៣៥ ភាគរយ ស្រី ៤៩,៣៨ ភាគរយ ធៀបនឹងប្រជាជនអាយុ ៥ឆ្នាំ។

### ១.២ អនុវិស័យ ការអប់រំបឋមសិក្សា

សាលាបឋមសិក្សាសរុប ៧ ៥៦១ សាលា៖ រដ្ឋ ៧ ១៤៤ កើន ៥៩ ឯកជន ៤១៧។ សាលាកុមារមេត្រីកម្រិតមធ្យមនិងអភិវឌ្ឍមាន ៥ ១៩៦ ស្មើនឹង ៧២,៧ ភាគរយ កើន ១៩ សាលា។ សាលារៀនមិនគ្រប់កម្រិតថ្នាក់មាន ៥៩៨ ស្មើនឹង ៨,៣ ភាគរយ ថយ ៨១ សាលា។ សិស្សបឋមសិក្សាសរុប ២ ១១១ ៦៣១ នាក់ ស្រី ១ ០១៨ ៣២៦ នាក់ ស្មើនឹង ៤៨,២ ភាគរយ៖ រដ្ឋ ២ ០២២ ០៦១ នាក់ ស្រី ៤៨,១៨ ភាគរយ ឯកជន ៨៩ ៥៧០ នាក់ ស្រី ៤៩,២២ ភាគរយ។ អត្រាពិតចូលរៀនថ្មី ៩៥,១ ភាគរយ ស្រី ៩៤ ភាគរយ ៖ រដ្ឋ ៩១ ភាគរយ ស្រី ៩០,១ ភាគរយ ឯកជន ៤,១ ភាគរយ ស្រី ៣,៩ ភាគរយ។ អត្រាពិតនៃការសិក្សា ៩៧,៧ ភាគរយ ស្រី ៩៨,២ ភាគរយ ៖ រដ្ឋ ៩៣,៥ ភាគរយ ស្រី ៩៣,៩ ភាគរយ ឯកជន ៤,១ ភាគរយ ស្រី ៣,៩ ភាគរយ។ អត្រាពិតនៃការសិក្សាសរុប ៩៧,៧ ភាគរយ ស្រី ៩៨,២ ភាគរយ៖ រដ្ឋ ៩៣,៥ ស្រី ៩៣,៩ ភាគរយ ឯកជន ៤,២ ស្រី ៤,៣ ភាគរយ។

សិស្សបឋមសិក្សា ៧៧ ៦៥៤ នាក់ ស្រី ៤២ ៧១០ នាក់ ស្មើនឹង ៥៥ ភាគរយ បានទទួលអាហារូបករណ៍ពីរាជរដ្ឋាភិបាល។

### ១.៣ អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស

អនុវិទ្យាល័យមាន ១ ២៤៥ សាលា៖ រដ្ឋ ១ ២៤៥ ថយ ៦ ឯកជន ៥៥។ សិស្សមធ្យមសិក្សាបឋមភូមិសរុប ៦០៨ ៩៥៥ នាក់ ស្រី ៣១៥ ០១៦ នាក់ ស្មើនឹង ៥១,៧៣ ភាគរយ៖ រដ្ឋ ៥៨៥ ៩៧១ នាក់ ស្រី ៥១,៨ ភាគរយ ឯកជន ២២ ៩៨៤ នាក់ ស្រី ៤៩,៥ ភាគរយ។ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ ៥៧,៦ ភាគរយ ស្រី ៦១,៥ ភាគរយ៖ រដ្ឋ ៥៥,៧ ភាគរយ ស្រី ៥៩,៦ ឯកជន ១,៩ ភាគរយ ស្រី ១,៩ ភាគរយ។

វិទ្យាល័យមាន ៦០៨ សាលា៖ រដ្ឋ ៤៨៦ កើន ២៣ ឯកជន ១២២។ សិស្សមធ្យមសិក្សាទុតិយភូមិសរុប ២៩៦ ៧២៤ នាក់ ស្រី ១៥១ ៧៨២ នាក់ ស្មើនឹង ៥១,១៥ ភាគរយ ៖ រដ្ឋ ២៧៩ ៤៨០ នាក់ ស្រី ៥១,៣ ភាគរយ ឯកជន ១៧ ២៤៤ នាក់ ស្រី ៤៨,៣ ភាគរយ។ វិទ្យាល័យធនធាន ៣៦។ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ២៦,៥ ភាគរយ ស្រី ២៨,១ ភាគរយ ៖ រដ្ឋ ២៥,១ ភាគរយ ស្រី ២៦,៧ ឯកជន ១,៤ ភាគរយ ស្រី ១,៤ ភាគរយ។

សិស្សអប់រំបច្ចេកទេសសាលារដ្ឋមាន ១ ១៤៨ នាក់ ស្រី ៤០,៤១ ភាគរយ សិក្សាលើមុខជំនាញអគ្គិសនី អេឡិចត្រូនិច ក្សេត្រសាស្ត្រ បសុវប្បកម្ម។

ឃុំ/សង្កាត់ ១៣៨ លើ ១ ៦៤៦ ស្មើនឹង ៨,៥ ភាគរយ មិនទាន់មានអនុវិទ្យាល័យ និងស្រុក ៥ លើ ១៩៧ ស្មើនឹង ២,៥ ភាគរយ មិនទាន់មានវិទ្យាល័យ ដោយសារស្ថានភាពភូមិសាស្ត្រ និងស្ថានភាពប្រជាសាស្ត្រមិនអំណោយផល ជាពិសេសនៅតំបន់កោះ និងតំបន់ព្រៃភ្នំ ដែលប្រជាពលរដ្ឋរស់នៅរាយប៉ាយ។

លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ៩៣,៧២ ភាគរយ ស្រី ៩៦,៣៧ ភាគរយ និងមធ្យមសិក្សាទុតិយភូមិ ៦២,១៨ ភាគរយ ស្រី ៦៥,៤៦ ភាគរយ។

សិស្សមធ្យមសិក្សាបឋមភូមិ ៦៩ ៥១៤ នាក់ ស្រី ៦០ ភាគរយ និងសិស្សមធ្យមសិក្សាទុតិយភូមិ ៣ ៦០០ ស្រី ៦០ ភាគរយ បានទទួលអាហារូបករណ៍ពីរាជរដ្ឋាភិបាល។

### ១.៤ អនុវិស័យ ការអប់រំឧត្តមសិក្សា

គ្រឹះស្ថានឧត្តមសិក្សាសរុប ១២១ កើន ៣៖ រដ្ឋ ៤៨ និងឯកជន ៧៣ មានទីតាំងនៅ ២០ ខេត្ត និងរាជធានីភ្នំពេញ។ គ្រឹះស្ថានឧត្តមសិក្សា ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡាមាន ៧៣ (រដ្ឋ១៣ និងឯកជន ៦០)។ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្ររងមាន ២៣ ៧៤៦ នាក់ ស្រី ៤៧,៩៤ ភាគរយ ថ្នាក់បរិញ្ញាបត្រមាន ១៧៤ ១៤២ នាក់ ស្រី ៤៦,០៥ ភាគរយ។ និស្សិតអាហារូបករណ៍ ២៦ ១៧៧ នាក់ ស្រី ៤៥,៩៤ ភាគរយ។ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ១៨ ៧២៣ នាក់ ស្រី ២១,៧៨ ភាគរយ ថ្នាក់បណ្ឌិត ១ ២២៩ នាក់ ស្រី ៥,១៣ ភាគរយ។

### ១.៥ អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ

អ្នករៀនក្នុងកម្មវិធីអក្ខរកម្មវិជ្ជាជីវៈមាន ២២ ៦៥២ នាក់ ស្រី ៦៩,៣៨ ភាគរយ៖ កម្មវិធីគ្រប់គ្រងដោយក្រសួង ២០ ០៨០ នាក់ ស្រី ៦៩,៦៤ ភាគរយ និងគាំទ្រដោយដៃគូអភិវឌ្ឍ ២ ៥៧២ នាក់ ស្រី ៦៧,៣៤ ភាគរយ។ មជ្ឈមណ្ឌលសិក្សាសហគមន៍ ៣៥៣ កន្លែង អ្នករៀន ៩ ៩៤៩ នាក់ ស្រី ៦៤,៦៩ ភាគរយ។ សិស្សចូលរៀនកម្មវិធីសមមូលបឋមសិក្សា ៥ ១៦៤នាក់ ស្រី ៥០,៩៦ ភាគរយ។ សិស្សកម្មវិធីចូលរៀនឡើងវិញ ១២ ៥៨២ នាក់ ស្រី ៤៥,៥៤ ភាគរយ។

### ១.៦ អនុវិស័យ ការអភិវឌ្ឍយុវជន

ក្រុមប្រឹក្សាយុវជនមាន ៤៥១ ក្រុម ដែលមានសមាជិក ២៩៦ ៣៦២ នាក់ ស្រី ៦២,៨ ភាគរយ និងក្រុមប្រឹក្សាកុមារ ៧ ៩៣១ ក្រុម ដែលមានសមាជិក ១ ៤៧១ ៥៤២ នាក់ ស្រី ៣៧,៩ ភាគរយ។ បានបណ្តុះបណ្តាលជំនាញខ្លីដល់យុវជន ១ ៣៨៩ នាក់ ស្រី ៥៧,៣១ ភាគរយ និងបណ្តុះបណ្តាលលើការងារស្ម័គ្រចិត្ត ៨០០ នាក់ ស្រី ៣៣,៣ ភាគរយ។

### ១.៧ អនុវិស័យ ការអប់រំកាយ និងកីឡា

ប្រកួតកីឡាចំបាប់ជ្រើសរើសជើងឯកអាស៊ីអាគ្នេយ៍ កម្ពុជាទទួលបានមេដាយមាស ៣ ប្រាក់ ១០ និងសំរឹទ្ធិ ១៧។ ប្រកួតកីឡាតេក្វាន់ដូអាយធីអេហ្វជើងឯកអាស៊ីអាគ្នេយ៍លើកទី១ នៅរាជធានីភ្នំពេញទទួលបានមេដាយមាស ៣១ ប្រាក់ ១០ សំរឹទ្ធិ ១១។

ជារួមនៅឆ្នាំ២០១៦ ការប្រកួតកីឡាជាលក្ខណៈអន្តរជាតិទទួលបានមេដាយ ១៩៩ គ្រឿង មាស ៦៧ ប្រាក់ ៥៤ និងសំរឹទ្ធិ ៧៨។

## ២- សមិទ្ធផលអន្តរអនុវិស័យ

### ២.១- ការងារបុគ្គលិក ការបណ្តុះបណ្តាលនិងហិរញ្ញវត្ថុ

បុគ្គលិកអប់រំសរុប ១១៦ ៤៥៧ នាក់ ស្រី ៤៤,៥៤ ភាគរយ។ បុគ្គលិកអប់រំបម្រើការនៅថ្នាក់ជាតិ ៣ ០៨២ នាក់ ស្រី ២៧,២៥ ភាគរយ និងថ្នាក់ក្រោមជាតិ ១១៣ ៣៧៥ នាក់ ស្រី ៤៥,២៦ ភាគរយ។ បុគ្គលិកជាប់កិច្ចសន្យា និងគ្រូកិច្ចសន្យាចំណេះទូទៅនិងអក្ខរកម្ម ៨ ៧៨៣ នាក់ ស្រី ៤១,២៦ ភាគរយ។ បានជ្រើសរើសគ្រូបង្រៀន ៣ ៩៨៨ នាក់ និងគ្រូបង្រៀនកម្រិតឧត្តមបង្រៀននៅឧត្តមសិក្សា ២៧ នាក់ ស្រី ៩ នាក់។

### ២.២- ការងារសំណង់សិក្សា

បានសាងសង់អគារសិក្សា ៦០ខ្នង ស្មើនឹង ១២៩បន្ទប់ និងអគារ ២ខ្នងនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញនិងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ បានសាង-សង់អគារសិក្សាសម្រាប់អនុវិទ្យាល័យ ៣៣ខ្នង ក្នុងនោះស្ថិតក្នុងឃុំមិនទាន់មានអនុវិទ្យាល័យ ១៩កន្លែង។ គិតត្រឹមខែកុម្ភៈ ឆ្នាំ២០១៧ អគារសិក្សាជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** មាន ៣ ៩៣២ ខ្នង ស្មើនឹង ២២ ២៥០ បន្ទប់។

### ២.៣ ការងារផែនការ-ស្ថិតិអប់រំ និងថវិកា

កម្ពុជាសម្រេចបានសកលកម្មការអប់រំនៅបឋមសិក្សា និងកាត់បន្ថយគម្លាតយេនឌ័រស្ទើរតែទាំងស្រុងនៃការអប់រំនៅកម្រិតមត្តេយ្យសិក្សា និងមធ្យមសិក្សាចំណេះទូទៅក្នុងក្របខណ្ឌគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ កម្ពុជានឹងខិតខំប្រឹងប្រែងថែមទៀតលើការបង្កើនប្រសិទ្ធភាព និងគុណភាពអប់រំនៅក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដើម្បី «**ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងការលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នានៅឆ្នាំ២០៣០**»។ ក្រសួងបាននិងកំពុងរៀបចំមូលដ្ឋាននីយកម្មគោលដៅអប់រំថ្មីនេះ តាមរយៈការរៀបចំចក្ខុវិស័យអប់រំកម្ពុជាឆ្នាំ២០៣០ ជាមួយនឹងការអភិវឌ្ឍធនធានមនុស្សស្របទៅនឹង «**គោលដៅអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ ២០១៥-២០២៥**» ដែលជាជំហានថ្មីមួយទៀតក្នុងការតម្រង់ទិសការអភិវឌ្ឍកម្ពុជា ឆ្លើយតបទៅនឹងមហិច្ឆតាកម្ពុជា ក្នុងការប្រែក្លាយខ្លួនទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។




### ២.៤- ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍ

| លរ | ដៃគូអភិវឌ្ឍធំៗទាំង១០ (ពាន់ដុល្លារ) | ចំណាយធនធានផ្ទាល់ខ្លួន២០១៦ | ផែនការឆ្នាំ២០១៧ | ផែនការឆ្នាំ២០១៨ |
|---|---|---|---|---|
| ១ | សហភាពអឺរ៉ុប | ២៤ ១៤៩ | ២៨ ៦១៥ | ៣១៦ |
| ២ | អង្គការស្បៀងអាហារពិភពលោក | ១៤ ៩១០ | N/A | N/A |
| ៣ | អង្គការយូនីសេហ្វ | ៩ ០៦៥ | ៦ ៥៦០ | ៣ ៣៧៥ |
| ៤ | ធនាគារអភិវឌ្ឍអាស៊ី | ៤ ៦០០ | ៥ ២០០ | ៣ ២០០ |
| ៥ | ប្រទេសស៊ុយអែត | ៣ ៩៧៥ | ១៣៩ | N/A |
| ៦ | ធនាគារពិភពលោក | ៣ ៨៤៨ | ៩ ១៧១ | ១០ ៨០១ |
| ៧ | ប្រទេសជប៉ុន | ៣ ៧១៤ | ២ ៨៣៤ | ២ ៧១៩ |
| ៨ | សាធារណរដ្ឋកូរ៉េ | ២ ៦៤៩ | ២ ៨០០ | N/A |
| ៩ | ប្រទេសនូវែលសេឡង់ | ២ ៦៣៥ | ៥៥០ | ៨៥២ |
| ១០ | សហរដ្ឋអាមេរិក | ២ ២៣៣ | N/A | N/A |
| | **សរុបភាគីផ្តល់ជំនួយចំនួន១០** | ៧១ ៨២០ | ៥៥ ៨៧១ | ២១ ៣១០ |
| | **សរុបភាគីផ្តល់ជំនួយទាំងអស់** | ៩០ ៤៨៤ | ៥៨ ២៥៨ | ២១ ៦២៤ |

*(ប្រភព CDC: ដកស្រង់ចេញពីទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧)*

## ៣. វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល

| សូចនាករស្នូលសម្រាប់សម្រេចគោលនយោបាយ | ស្ថានភាព ២០១៥-១៦ | ចំណុចដៅ ២០១៦-១៧ | ជាក់ស្តែង ២០១៦-១៧ | ចំណុចដៅ ២០១៩-២០ |
|---|---|---|---|---|
| **គោលនយោបាយទី១ ៖** *ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា* | | | | |
| ១. ភាគរយកុមារអាយុ៥ឆ្នាំក្នុងការអប់រំកុមារតូចគ្រប់រូបភាព | ៦៤,១% | ៦៦% | ៦៦,៣៤% | ៧២% |
| ២. ចំនួនស្រុកដែលមានអត្រាត្រួតថ្នាក់នៅបឋមសិក្សាតិចជាង ឬស្មើ ១០ ភាគរយ | ១៧១ | ១៧៦ | ១៧៣ | ១៩៣ |
| ៣. ចំនួនខេត្តដែលបានសម្រេចអត្រាបញ្ចប់មធ្យមសិក្សាបឋមភូមិយ៉ាងតិច ៤០ ភាគរយ | ៨ | ៩ | ១១ | ១៤ |
| ៤. អត្រាអក្ខរកម្មជនពេញវ័យ (អាយុ ១៥ ឡើង) | ៧៨,១% (ឆ្នាំ២០១៤) | ៧៩,៨% | ៧៨,១% (ឆ្នាំ២០១៥) | ៨៥% |
| ៥. វង្វាយតម្លៃតេស្តស្តង់ដាថ្នាក់ជាតិសិស្សថ្នាក់ ទី៣ លើមុខវិជ្ជាភាសាខ្មែរ និង គណិតវិទ្យា | | | | |
| ការអាន | ៤២,៧ | | ៣៥,២ (២០១៤-១៥) | កើន ៥ពិន្ទុ |
| គណិតវិទ្យា | ៤៣,៤ | | ៤១,០ (២០១៤-១៥) | កើន ៥ពិន្ទុ |
| ៦. ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានធ្វើការវាយតម្លៃ | ១០ | ៣០ | ៣៨ | ៩០ |
| ៧. ភាគរយគ្រូបង្រៀនបឋមសិក្សាមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ+២ | ៥៧% | ៥៨% | ៦៩,៦២% | ៦១% |
| ៨. ភាគរយគ្រូឧទ្ទេស (សាលាគរុ.មជ្ឈ.គរុ និងវិទ្យាស្ថានជាតិអប់រំ) មានបរិញ្ញាបត្រជាន់ខ្ពស់ | ១០% | ១៥% | ២០,២% | ២៤% |
| **គោលនយោបាយទី២ ៖** *ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់* | | | | |
| ៩. ចំនួននាយកសាលាបឋមសិក្សា និងមធ្យមសិក្សាទទួលបានការបណ្តុះបណ្តាលស្តីពីការងារគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល | N/A | ៥០០ | ៩៤៨ | ៥០០ |
| ១០. ភាគរយនៃការទូទាត់ថវិកា | ៩៤,៣% (២០១៥) | ៩៥% | ៩៤%* | ៩៥% |

*ប្រភព៖ *តួលេខបណ្តោះអាសន្ន*

## ៤. វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់

ក្រសួងបានដាក់ចេញនូវវិធានការកំណែទម្រង់១៥ ចំណុចដោយឈរលើមូលដ្ឋាននៃសសរស្តម្ភចំនួន៥ គឺ ១) ការអនុវត្តសកម្មភាពគោលនយោ-បាយគ្រូបង្រៀន ២)ការពិនិត្យឡើងពីកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងការកែលម្អបរិស្ថាន ៣)ការដាក់ឱ្យអនុវត្តអធិការកិច្ច ៤) ការពង្រឹងវង្វាយតម្លៃការសិក្សា និង៥) ការកែទម្រង់ឧត្តមសិក្សា។

| សសរស្តម្ភ | វឌ្ឍនភាពសំខាន់ៗ ក្នុងឆ្នាំ ២០១៦ |
|---|---|
| ១. ការអនុវត្តសកម្មភាពគោលនយោបាយគ្រូបង្រៀន | - កំពុងបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន ៧០០ នាក់ ឱ្យទៅជាគ្រូបង្រៀនកម្រិតឧត្តម<br>- កំពុងអភិវឌ្ឍមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ និង ភូមិភាគបាត់ដំបង ឱ្យក្លាយទៅជា វិទ្យាស្ថានគរុកោសល្យ (១២+៤)<br>- អនុម័តស្តង់ដាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងស្តង់ដានាយកសាលា<br>- កំពុងរៀបចំស្តង់ដាគ្រូបង្រៀន និងគន្លងអាជីពគ្រូបង្រៀន។ |
| ២. ការពិនិត្យឡើងពីកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងការកែលម្អបរិស្ថាន | - អនុម័តនិងផ្សព្វផ្សាយក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស<br>- ដាក់ឱ្យដំណើរការសាលារៀនជំនាន់ថ្មីនៅក្នុងវិទ្យាល័យព្រះស៊ីសុវត្ថិ<br>- អនុម័តនិងផ្សព្វផ្សាយឱ្យប្រើប្រាស់គោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌអប្បបរមា ស្តីពីទឹកស្អាត និងអនាម័យនៅតាមសាលារៀន<br>- អនុម័តនិងអនុវត្តសេចក្តីណែនាំស្តីពីចលនាប្រឡងប្រណាំងសាលារៀនស្អាត<br>- សាងសង់អគារសិក្សាមត្តេយ្យសិក្សាសហគមន៍ សាលាមត្តេយ្យសិក្សាធនធាន សាលាបឋមសិក្សា ផ្ទះគ្រូស្នាក់នៅ និងអគារការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក នៅតាមបណ្តាខេត្ត<br>- ជួសជុល និងកែលម្អមណ្ឌលប្រឡងមធ្យមសិក្សាទុតិយភូមិ ៤៧។ |
| ៣. ការដាក់ឱ្យអនុវត្តអធិការកិច្ច | - អនុម័តបញ្ញត្តិធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅ<br>- បានរៀបចំឧបករណ៍សម្រាប់ធ្វើអធិការកិច្ច សៀវភៅជំនួយស្មារតី អធិការកិច្ច និងទម្រង់របាយការណ៍អធិការកិច្ច<br>- បញ្ចប់ការបណ្តុះបណ្តាលអធិការអប់រំ ៣១ នាក់ ស្រី ៣ នាក់<br>- កំពុងបណ្តុះបណ្តាលអធិការអប់រំ ៧៣ នាក់ ស្រី ៩ នាក់។ |
| ៤. ការពង្រឹងវង្វាយតម្លៃការសិក្សា | - បំប៉នមន្ត្រីជំនាញអំពីការងារតេស្តវង្វាយតម្លៃថ្នាក់ជាតិ ថ្នាក់តំបន់ និង អន្តរជាតិ មានអ្នកចូលរួម ៣៩៥ នាក់ ស្រី ៧៧<br>- ធ្វើតេស្តល្បឿនអំណានថ្នាក់ទី១ ទី២ និងទី៣ នៃសាលាបឋមសិក្សា<br>- ធ្វើតេស្តវង្វាយតម្លៃថ្នាក់តំបន់កម្រិតបឋមសិក្សា និងរៀបចំតេស្តវាយតម្លៃសិស្សកម្រិតអន្តរជាតិសម្រាប់ការអភិវឌ្ឍ។ |
| ៥. ការកែទម្រង់ឧត្តមសិក្សា | - កែលម្អនីតិវិធី និងដំណើរការទទួលស្គាល់គុណភាពអប់រំ លើគ្រឹះស្ថានឧត្តមសិក្សា និងបានវាយតម្លៃសាកល្បងលើគ្រឹះស្ថាន ឧត្តមសិក្សា ៣៨<br>- ព្រាងស្តង់ដាទទួលស្គាល់គុណភាពអប់រំកម្រិតបណ្ឌិត<br>- ពង្រឹងនិងពង្រីកការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្មនិងគណិតវិទ្យានៅសាកល វិទ្យាល័យភូមិន្ទភ្នំពេញ និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា<br>- ត្រៀមបង្កើតគណៈកម្មាធិការវិទ្យាសាស្ត្រកម្ពុជាសម្រាប់ការស្រាវជ្រាវ និងការបណ្តុះបណ្តាលថ្នាក់បណ្ឌិត និងការបង្កើតសាលាថ្នាក់បណ្ឌិត។ |